ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
"រ.ទ.ស.ភ"
លេខ .....................

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី១៦ អាណត្តិទី៥
# របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

នាថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥ ចាប់ពីម៉ោង ១៤និង០០នាទីល្ងាច នៅសណ្ឋាគារសុខា ក្រុងព្រះសីហនុ **ឯកឧត្តម សឹម ណារ៉ា** ជាប្រធានក្រុមប្រឹក្សាភិបាលនៃរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី៥ បានអញ្ជើញចូលរួមជាអធិបតីដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី១៦ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ(រ.ទ.ស.ភ)។

នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី១៦ នេះ អង្គប្រជុំបានពិនិត្យ និងពិភាក្សាយ៉ាងផុសផុលលើខ្លឹមសារលម្អិតនៃរបាយការណ៍ និងផ្អែកលើតម្រូវការចាំបាច់របស់ រ.ទ.ស.ភ ក្រុមប្រឹក្សាភិបាលបានសម្រេច និងផ្តល់អនុសាសន៍ណែនាំដូចខាងក្រោម៖

១. ឯកភាពទទួលជ្រាបជារបាយការណ៍លើ លទ្ធផលការងារសវនកម្មផ្ទៃក្នុង ឆមាសទី១ ឆ្នាំ២០១៥ ដែលបានធ្វើឡើងនៅសវនដ្ឋានពីរគឺ នាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស និង នាយកដ្ឋានផលិតកម្ម និងផ្គត់ផ្គង់ទឹក។ ក្រុមប្រឹក្សាភិបាលក៏បានស្នើសុំ គណៈកម្មាធិការសវនកម្ម ណែនាំដល់អង្គភាពសវនកម្មផ្ទៃក្នុងក្នុងការអនុវត្តការងារ និងធ្វើរបាយការណ៍ឱ្យបានល្អ។

២. ឯកភាពលើ របាយការណ៍លទ្ធផលកិច្ចលទ្ធកម្មអនុវត្ត ក្នុងត្រីមាសទី២ ឆ្នាំ២០១៥ និងអនុម័ត-ឯកភាពលើការកែសម្រួលផែនការលទ្ធកម្ម សម្រាប់ឆមាសទី២ ឆ្នាំ២០១៥ ដែលនឹងត្រូវសុំការអនុម័តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទៅលើ កញ្ចប់លទ្ធកម្មពីរគឺ លទ្ធកម្មទំនិញចំនួន ១៩មុខ និងលទ្ធកម្មសេវាចំនួន ២មុខ ដែលគ្រោងទឹកប្រាក់សរុបចំនួន ៦.០៣០.៤៣៤.៧០០រៀល។

៣. ឯកភាពលើ ការចំណាយមូលនិធិបម្រើផលប្រយោជន៍សង្គម ក្នុងត្រីមាសទី២ ឆ្នាំ២០១៥ ដែលមានទឹកប្រាក់សរុបចំនួន ៦១០.៤៧៣.០៥០រៀល។

៤. ឯកភាពទាំងស្រុងលើខ្លឹមសារនៃ របាយការណ៍លទ្ធផលការងារ ត្រីមាសទី២-ឆមាសទី១ ឆ្នាំ២០១៥៖
- ដាក់បំពង់ថ្មី ៣១.៩៤០ ម៉ែត្រ
- បណ្តាញចូលផ្ទះ៖ ៣.៨០១ បណ្តាញ (បណ្តាញប្រជាពលរដ្ឋមានចំណូលទាបមាន ៥៧៣ បណ្តាញ)
- ទឹកស្អាតផលិតបាន ៤០.១៩៣.៩៣៣ ម៣
- បរិមាណទឹកលក់ ៣៦.៤៣៧.៧៧៩ ម៣
- អត្រាទឹកគ្មានចំណូល ៩,៣៥%
- ថ្លៃលក់ទឹកមធ្យម ១,០២៤ រៀល/ម៣


ទីស្នាក់ការ : លេខ ៤៥ ផ្លូវ ១០៦ សង្កាត់ ស្រះចក ខណ្ឌ ដូនពេញ, ទូរស័ព្ទ: ០២៣-៧២៤-០៤៦ Email: admin@ppwsa.com.kh

- ចំណូលថ្លៃទឹក ៣៧.២៥៤.៣៤៩.០០០ រៀល
- ចំណូលសរុប ៤៩.៧៦៦.០៤២.៥០០ រៀល
- ចំណាយសរុប ៤០.០២២.៦៧៦.៤០០ រៀល
- ការសាងសង់រោងចក្រនិរោធន៍ ជំហាន២ ៖ រ.ទ.ស.ភ បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនចំនួន ៤ លើការផ្គត់ផ្គង់សម្ភារ សម្រាប់អនុវត្តគម្រោងសាងសង់រោងចក្រនិរោធន៍ ជំហាន២។

ក្រុមប្រឹក្សាភិបាលក៏បានឯកភាពទាំងស្រុងលើ ទិសដៅការងារត្រីមាសទី៣ ឆ្នាំ២០១៥៖

- ដាក់បំពង់ថ្មី ៣០.៨១៨ ម៉ែត្រ
- បណ្តាញចូលផ្ទះ៖ ៤.២២៥ បណ្តាញ
- ទឹកស្អាតផលិតបាន ៣៩.១១៩.៥០០ ម$^{៣}$
- បរិមាណទឹកលក់ ៣៦.៣៨១.២០០ ម$^{៣}$
- ចំណូលសរុប ៤៧.៩៧៤.១៣៧.០០០ រៀល
- ចំណាយសរុប ៣៤.០៨៣.០៣៩.០០០ រៀល

៥. ឯកភាពលើ លទ្ធផលនៃការសិក្សាបុរេសមិទ្ធិលទ្ធភាពនៃគម្រោងផ្គត់ផ្គង់ទឹកស្អាតវាំលិច ស្រុកជុំគិរី ខេត្តកំពត និងសម្រេចឱ្យបន្តការសិក្សាគម្រោងលម្អិតមានរយៈពេល ៣ខែទៀត ដើម្បីមានមូលដ្ឋានច្បាស់លាស់ក្នុងការលើកសំណើសុំរាជរដ្ឋាភិបាលជាគម្រោងអាទិភាពពិសេសសម្រាប់ជួយដល់កងទ័ព។

៦. ឯកភាពទទួលជ្រាបជាព័ត៌មាន និងគាំទ្រសំណើរបស់ រ.ទ.ស.ភ ដើម្បីស្នើសុំអន្តរាគមន៍ទៅសាលារាជធានីភ្នំពេញ ដើម្បីផ្តល់សិទ្ធិឱ្យ រ.ទ.ស.ភ កាត់ថ្នល់គ្រប់ប្រភេទ ដើម្បីពង្រីកបណ្តាញនៅទូទាំងរាជធានីភ្នំពេញ ២០១៥-២០២០។

៧. ឯកភាព-អនុម័តគោលការណ៍លើ ការទិញបំពង់ទំហំ ៧០០ម.ម ដោយផ្ទាល់ពីក្រុមហ៊ុន Saint Gobain PAM សម្រាប់គម្រោងរុះរើបំពង់មេនាំទឹកទំហំ ៧០០ម.ម ដែលនាំទឹកស្អាតចេញពីរោងចក្រភូមិព្រែក (ជាប់នឹងរបងខាងជើងសាលាពេទ្យ)។

៨. អនុម័តឱ្យបន្តការសិក្សាលើ គម្រោងពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅរាជធានីភ្នំពេញ ឆ្នាំ២០១៧-២០៣០ ។ ក្រុមប្រឹក្សាភិបាលនឹងបើកកិច្ចប្រជុំវិសាមញ្ញ នាពេលខាងមុខ ដើម្បីបន្តពិភាក្សាលើការងារនេះបន្តទៀត។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង ១៨:៣០ នាទីល្ងាច នាថ្ងៃ ខែ និងឆ្នាំដដែល ស្ថិតក្រោមបរិយាកាសទទួលខុសត្រូវខ្ពស់ និងឯកភាពគ្នា។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៥

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**



អាសយដ្ឋាន: លេខ៤៥ ផ្លូវ ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ទូរស័ព្ទ: ៨៥៥ (២៣) ៧២៤ ០៤៦ Email: admin@ppwsa.com.kh